ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**ខ្លឹមសារស្ដីពីជំនួបសម្ដែងការគួរសម និងជម្រាបលារបស់ ឯកឧត្តម Mohammed Ismaeil A. Dahlwy ឯកអគ្គរាជទូតអារ៉ាប៊ីសាអូឌីតប្រចាំកម្ពុជា ចំពោះ ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា**

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតជូន **ឯកឧត្តម** Mohammed Ismaeil A. Dahlwy ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្ដែងការគួរសម និងជម្រាបលា ក្នុងឱកាសដែលឯកឧត្តមបានបញ្ចប់បេសកកម្មការទូតនៅកម្ពុជា។

ក្នុងអំឡុងពេលនៃជំនួប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអបអរសាទរជូនចំពោះ ឯកឧត្តមឯកអគ្គរាជទូត ដែលបានបញ្ចប់អាណត្តិបេសកកម្មការទូតដោយជោគជ័យ និងកោតសរសើរចំពោះការរួមចំណែកដ៏មានតម្លៃរបស់ឯកឧត្តម ក្នុងការពង្រឹងពង្រីកទំនាក់ទំនងជាមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងអារ៉ាប៊ីសាអូឌីត។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងឯកឧត្តមឯកអគ្គរាជទូត បានសម្ដែងនូវការពេញចិត្តចំពោះការរីកចម្រើនជាបន្តបន្ទាប់នៃទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរ ចាប់តាំងពីការបង្កើតទំនាក់ទំនងការទូត។ ភាគីទាំងពីរបានគូសបញ្ជាក់ពីសារៈសំខាន់នៃការរក្សាសន្ទុះនៃទំនាក់ទំនង តាមរយៈការបន្តផ្លាស់ប្ដូរទស្សនកិច្ចកម្រិតខ្ពស់ និងទស្សនកិច្ចទៅវិញទៅមក។ ភាគីទាំងពីរបានរំលឹកឡើងវិញ ដោយក្ដីសោមនស្សរីករាយចំពោះដំណើរទស្សនកិច្ចផ្លូវការរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភាកម្ពុជា ទៅកាន់ព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត កាលពីខែធ្នូ ឆ្នាំ២០២៤ និងដំណើរទស្សនកិច្ចផ្លូវការរបស់ **ឯកឧត្តមបណ្ឌិត អាប់ឌុលឡា ម៉ូហាម៉េដ អ៊ីប្រាហ៊ីម អាល់-សេក្ខ** ( Abdullah Mohammed Ibrahim Al-Sheikh ) ប្រធានសភាអារ៉ាប៊ីសាអូឌីត នៅកម្ពុជាកាលពីខែកក្កដា ឆ្នាំ២០២៥។ ទន្ទឹមនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** ក៏បានរំលឹកពីជំនួបប្រកបដោយផ្លែផ្ការវាង **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និង**ព្រះអង្គម្ចាស់ ហ្វាសាល់ ប៊ីន ហ្វាហាន់ អាល់ សូដ** ( H.H. Prince Faisal Farhan Al Saud ) រដ្ឋមន្ត្រីការបរទេស នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ ក្នុងអំឡុងពេលដែលព្រះអង្គយាងមកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា។

ភាគីទាំងពីរក៏បានកត់សម្គាល់ដោយក្ដីពេញចិត្តចំពោះការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្ដីពីការលើកកម្ពស់ទំនាក់ទំនងពាណិជ្ជកម្មរវាងកម្ពុជា និងអារ៉ាប៊ីសាអូឌីត កាលពីឆ្នាំមុន។ ក្នុងន័យនេះ ឯកឧត្តមឯកអគ្គរាជទូត បានជម្រាបអំពីគម្រោងទស្សនកិច្ចរបស់គណៈប្រតិភូធុរកិច្ចអារ៉ាប៊ីសាអូឌីតមកពីវិស័យផ្សេងៗ មកកាន់កម្ពុជា នាពេលអនាគតដ៏ខ្លីខាងមុខ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការក្នុង

វិស័យកសិកម្ម សន្តិសុខស្បៀង ថាមពល និងវិស័យសក្តានុពលផ្សេងៗទៀត។ ឯកឧត្តមឯកអគ្គរាជទូត បានបញ្ជាក់ជាថ្មីនូវផែនការរបស់ប្រទេសអារ៉ាប៊ីសាអូឌីតក្នុងការបើកស្ថានទូតនៅរាជធានីភ្នំពេញ នាពេលអនាគត។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ ដើម្បីពង្រឹងការតភ្ជាប់ និងទេសចរណ៍ ដោយសង្កត់ធ្ងន់លើសក្តានុពលសម្រាប់ការហោះហើរត្រង់រវាងរាជធានីភ្នំពេញ និងទីក្រុងរីយ៉ាដ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាល អារ៉ាប៊ីសាអូឌីត ដែលបានផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជា ហើយសង្ឃឹមថា អារ៉ាប៊ីសាអូឌីតនឹងបន្តផ្តល់អាហារូបករណ៍បន្ថែមទៀត ជាពិសេសផ្នែកវិទ្យាសាស្ត្រ និងវិស្វកម្ម ដើម្បីគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្សរបស់កម្ពុជាបន្ថែមពីលើកម្មវិធីសិក្សាផ្នែកសាសនាដែលមានស្រាប់។

ឯកឧត្តមឯកអគ្គរាជទូត បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធកម្ពុជានានា ដែលបានផ្តល់កិច្ចសហប្រតិបត្តិការ និងការគាំទ្រយ៉ាងជិតស្និទ្ធ ក្នុងអាណត្តិរបស់ឯកឧត្តម។ ឯកឧត្តម ក៏បានបញ្ជាក់ជាថ្មីអំពីការប្តេជ្ញាចិត្តរបស់អារ៉ាប៊ីសាអូឌីត ក្នុងការជំរុញកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា និងបានសម្តែងសុទិដ្ឋិនិយមយ៉ាងខ្លាំងចំពោះទស្សនៈវិស័យនៃទំនាក់ទំនងទ្វេភាគីកម្ពុជា-អារ៉ាប៊ីសាអូឌីត។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជូនពរ ឯកឧត្តមឯកអគ្គរាជទូត និងបានបញ្ជាក់នូវការត្រៀមខ្លួនរបស់កម្ពុជា ក្នុងការផ្តល់ការគាំទ្រ និងកិច្ចសហប្រតិបត្តិការដល់ឯកអគ្គរាជទូតអារ៉ាប៊ីសាអូឌីតថ្មី ដើម្បីពង្រឹងចំណងមិត្តភាពទ្វេភាគីបន្ថែមទៀត៕